**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation Religion King**

លេខ / N° ០០៧/២០ សជ.ធឥ.ក.

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលរបស់សាជីវកម្មធានាឥណទានកម្ពុជា

## ក្រុមប្រឹក្សាភិបាល

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្ដីពីបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្ដីពីការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩២៦ អនក្រ.តត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្ដីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញលក្ខន្តិកៈសាជីវកម្មធានាឥណទានកម្ពុជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់សាជីវកម្មធានាឥណទានកម្ពុជា



មហាវិថីព្រះនរោត្តម, អគារអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ជាន់ទី២៥), រាជធានីភ្នំពេញ
Preah Norodom Blvd, General Department of Customs and Excise of Cambodia Building (25th Floor), Phnom Penh.

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលរបស់សាជីវកម្មធានាឥណទានកម្ពុជា (ស.ធ.ក.) ដើម្បីធានាបាននូវអភិបាលកិច្ចល្អ, តម្លាភាព, និងគណនេយ្យភាពរបស់ **ស.ធ.ក.**។

**ប្រការ ២ .-**

គណៈកម្មាធិការសវនកម្ម មានសមាសភាព ដូចខាងក្រោម÷

- សមាជិកក្រុមប្រឹក្សាភិបាល តំណាងឯករាជ្យមកពីវិស័យឯកជន — ប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល តំណាងពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ — សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាល តំណាងមកពីធនាគារជាតិនៃកម្ពុជា — សមាជិក

ក្រុមប្រឹក្សាភិបាល អាចតែងតាំងសមាសភាពបន្ថែម នៃគណៈកម្មាធិការសវនកម្ម តាមការចាំបាច់។

សមាសភាពជាក់ស្តែង នៃគណៈកម្មាធិការសវនកម្ម ត្រូវកំណត់ដោយសេចក្តីសម្រេចដាច់ដោយឡែករបស់ក្រុមប្រឹក្សាភិបាល។

**ប្រការ ៣ .-**

គណៈកម្មាធិការសវនកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងគោលការណ៍គណនេយ្យ
- ត្រួតពិនិត្យដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការបង្ហាញព័ត៌មាន
- ត្រួតពិនិត្យការជ្រើសរើស និងការអនុវត្តការងាររបស់សវនករឯករាជ្យពីខាងក្រៅ
- ត្រួតពិនិត្យអនុលោមភាពផ្នែកច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងនីតិវិធីពាក់ព័ន្ធជាធរមាន
- ត្រួតពិនិត្យដំណើរការនៃការបំពេញការងាររបស់សវនករផ្ទៃក្នុង
- ស្នើឡើងនូវគោលការណ៍, វិធាន, និងដំណោះស្រាយនានា ដើម្បីធានាបាននូវអភិបាលកិច្ចល្អ, តម្លាភាព និងគណនេយ្យភាពរបស់ **ស.ធ.ក.** ជូនទៅក្រុមប្រឹក្សាភិបាល
- អនុវត្តកិច្ចការផ្សេងទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល។

**ប្រការ ៤ .-**

គណៈកម្មាធិការសវនកម្ម ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច ១ដង ក្នុង ១ត្រីមាស។

គណៈកម្មាធិការសវនកម្ម អាចរៀបចំកិច្ចប្រជុំតាមការចាំបាច់ តាមសំណើររបស់ប្រធាន ឬ សមាជិកភាគច្រើន។

**ប្រការ ៥ .-**

សមាជិកទាំងអស់ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ សមាជិកអវត្តមាន មិនអាចចាត់អ្នកតំណាង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មាធិការសវនកម្មបានទេ។

គណៈកម្មាធិការសវនកម្ម អាចអញ្ជើញថ្នាក់ដឹកនាំ បុគ្គលិករបស់ **ស.ធ.ភ.** និងអ្នកជំនាញការ ព្រមទាំងភាគីពាក់ព័ន្ធ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម តាមការចាំបាច់។

គណៈកម្មាធិការសវនកម្ម អាចរៀបចំកិច្ចប្រជុំបាន លុះត្រាតែមានវត្តមានរបស់សមាសភាពភាគច្រើនចូលរួម។

**ប្រការ ៦ .-**

គណៈកម្មាធិការសវនកម្ម ត្រូវរៀបចំមុខងារ និងភារកិច្ច (Terms of Reference) របស់គណៈកម្មាធិការសវនកម្ម ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច។

**ប្រការ ៧ .-**

គណៈកម្មាធិការសវនកម្ម ត្រូវមានរបាយការណ៍នៃរាល់កិច្ចប្រជុំ និងត្រូវផ្តល់របាយការណ៍នេះជូនក្រុមប្រឹក្សាភិបាល យ៉ាងយូរ ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកិច្ចប្រជុំ។

**ប្រការ ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩ .-**

គណៈកម្មាធិការសវនកម្ម មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃសុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃ ២៥ ខែ ធ្នូ ឆ្នាំ២០២០*

**សាជីវកម្មធានាឥណទានកម្ពុជា**

**ប្រធានក្រុមប្រឹក្សាភិបាល**

**រស់ សីលវ៉ា**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ធនាគារជាតិនៃកម្ពុជា
- សមាជិកក្រុមប្រឹក្សាភិបាលរបស់ **ស.ធ.ក.**
- ឯកសារ-កាលប្បវត្តិ